PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

PRUទ្រព្យ អេលីត

បង្កើនទ្រព្យសម្បត្តិ *ការពារមរតកគ្រួសារ*



ហេតុអ្វីត្រូវជ្រើសរើស PRUទ្រព្យ អេលីត?

PRUទ្រព្យ អេលីត ជាដំណោះស្រាយធានារ៉ាប់រងអាយុជីវិតដ៏មានគុណតម្លៃ ដែលផ្តល់នូវការការពារអាយុជីវិតរយៈពេលវែង ព្រមទាំងអត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ និងការផ្តល់សុវត្ថិភាពហិរញ្ញវត្ថុសម្រាប់ពេលអនាគត។ ផលិតផលនេះ នឹងជួយធានានូវអនាគតហិរញ្ញវត្ថុរបស់លោកអ្នក និងក្រុមគ្រួសារលោកអ្នក ជាមួយប្រាក់ចំណូលទៀងទាត់ និងអត្ថប្រយោជន៍ពេលដល់កាលកំណត់ ដើម្បីគាំទ្រតម្រូវការនៃការរស់នៅ ការសម្រេចគោលដៅហិរញ្ញវត្ថុ ការចូលនិវត្តន៍ និងការរៀបចំកេរមរតករបស់លោកអ្នក។

អត្ថប្រយោជន៍ដែលទទួលបាន នៅពេលដែលលោកអ្នកជាវផលិតផលធានារ៉ាប់រង

បង់បុព្វលាភត្រឹមតែ 7 ឆ្នាំ ទទួលបានការការពាររយៈពេលវែងរហូតដល់អាយុ 75 ឆ្នាំ

ទទួលបានចំណូលជាបន្តបន្ទាប់

ទទួលបានចំណូលប្រចាំឆ្នាំ **5%** គិតពីឆ្នាំទី 2

ចាប់ផ្តើមទទួលបានអត្ថប្រយោជន៍តាំងពីដំណាក់កាលដំបូង ដោយមិនរង់ចាំរហូតដល់ បណ្ណសន្យារ៉ាប់រងដល់កាលកំណត់ឡើយ។



ការការពារដែលកើនឡើង

អត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍កើនឡើងរហូតដល់ **700%** នៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង និងរហូតដល់ **2,100%** ក្នុងករណីគ្រោះថ្នាក់ចៃដន្យ

ការការពារកើនឡើងស្របតាមការកើនឡើងនៃទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់លោកអ្នក។



ទ្រព្យសម្បត្តិសម្រាប់អនាគត

ទទួលបានអត្ថប្រយោជន៍ពេលដល់កាលកំណត់រហូតដល់ **750%** នៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង

បង្កើតតម្លៃហិរញ្ញវត្ថុដ៏រឹងមាំក្នុងរយៈពេលវែង ដើម្បីគាំទ្រតម្រូវការហិរញ្ញវត្ថុនាពេលអនាគត។



មរតកសម្រាប់មនុស្សជាទីស្រលាញ់

គម្រោងតែមួយ សម្រាប់ពីរជំនាន់

ចាប់ផ្តើមពីវ័យក្មេង ដើម្បីទទួលបានការបង់បុព្វលាភទាប និងបន្តតម្លៃនៃបណ្ណសន្យារ៉ាប់រងទៅកាន់មនុស្សជាទីស្រឡាញ់របស់លោកអ្នក តាម រយៈការផ្ទេរកម្មសិទ្ធិបណ្ណសន្យារ៉ាប់រង។



ដំណើរការទិញងាយស្រួល ដោយមិនតម្រូវឱ្យពិនិត្យសុខភាព



លក្ខណៈពិសេសរបស់ផលិតផល៖

អាយុកំណត់នៃអ្នកត្រូវបានធានារ៉ាប់រង	**30** ថ្ងៃ - **60** ឆ្នាំ
អាយុម្ចាស់បណ្ណសន្យារ៉ាប់រង	**18** ឆ្នាំឡើងទៅ
អាយុផុតកំណត់ធានារ៉ាប់រង	រហូតដល់ **65, 70, 75** ឆ្នាំ អាស្រ័យលើជម្រើសរបស់អតិថិជន
រយៈពេលកំណត់នៃ បណ្ណសន្យារ៉ាប់រង	ការពារយរហូតដល់ **65, 70, 75** ឆ្នាំ (រយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រងតិចបំផុត 15ឆ្នាំ ត្រូវបានអនុវត្តចំពោះអ្នកត្រូវបានធានារ៉ាប់រងដែលមានអាយុ 60 ឆ្នាំ នៅពេលបណ្ណសន្យារ៉ាប់រងចាប់ផ្តើមមានសុពលភាព)
រយៈពេលបង់បុព្វលាភធានារ៉ាប់រង	ការបង់ប្រាក់ក្នុងរយៈពេលកំណត់៖ **7** ឆ្នាំ
របៀបបង់ប្រាក់	ប្រចាំត្រីមាស ប្រចាំឆមាស និង ប្រចាំឆ្នាំ
វិធីបង់ប្រាក់	ផ្ទេរប្រាក់តាមធនាគារ ឬ **Mobile Wallet**
ចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង	ចាប់ពី **3,000** ដុល្លារសហរដ្ឋអាមេរិកឡើងទៅ
អត្ថប្រយោជន៍ក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍	រហូតដល់ **700%** នៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រងនឹងផ្តល់ជូនក្នុងករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ មិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ រហូតដល់ **2,100%** នៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រងនឹងផ្តល់ជូនក្នុងករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដោយសារគ្រោះថ្នាក់ចៃដន្យ
អត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ	**5%** នៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង ចាប់ពីដើមឆ្នាំទី **2** រហូតដល់កាលបរិច្ឆេទផុតកំណត់នៃបណ្ណសន្យារ៉ាប់រង
អត្ថប្រយោជន៍ពេលដល់កាលកំណត់	ផ្តល់ជូន **750%, 700%** និង **650%** នៃចំនួនទឹកប្រាក់ធានារ៉ាប់រង នៅពេលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ **75**ឆ្នាំ **70**ឆ្នាំ និង **65**ឆ្នាំ។
ទឹកដែនហានិភ័យដែលត្រូវបានធានា	ទូទាំងពិភពលោក

តារាងលម្អិតបង្ហាញអំពីអត្ថប្រយោជន៍ធានារ៉ាប់រងនៃផលិតផល៖

លោក ក អាយុ **35** ឆ្នាំ ជាម្ចាស់អាជីវកម្ម។ គាត់បានដាវ **PRUទ្រព្យ អេលីត** ជាមួយចំនួនទឹកប្រាក់ធានារ៉ាប់រង **10,000ដុល្លារអាមេរិក** សម្រាប់ការការពារអាយុជីវិតរហូតដល់គាត់មានអាយុ **70ឆ្នាំ**។

ករណីសុខសប្បាយ

លោក ក រស់នៅសុខសប្បាយដល់កាលបរិច្ឆេទពេលដល់កាលកំណត់

ឆ្នាំបណ្ណសន្យារ៉ាប់រង	1	2	3	4	5	6	7	8	9	10	.....	35	អត្ថប្រយោជន៍ពេលដល់កាលកំណត់
បុព្វលាភធានារ៉ាប់រង	7,500	7,500	7,500	7,500	7,500	7,500	7,500				.....		
ចំណូលប្រចាំឆ្នាំ		500	500	500	500	500	500	500	500	500	.....	500	
អត្ថប្រយោជន៍ពេលដល់កាលកំណត់	.....												70,000

ចំណូលប្រចាំឆ្នាំសរុប **$17,000** + អត្ថប្រយោជន៍ពេលដល់កាលកំណត់ **$70,000** = អត្ថប្រយោជន៍សរុប **$87,000** | បុព្វលាភធានារ៉ាប់រងសរុប **$52,500**

ករណីមរណភាព

លោក ក ទទួលមរណភាពដោយសារគ្រោះថ្នាក់ចរាចរណ៍ នៅឆ្នាំទី7

ឆ្នាំបណ្ណសន្យារ៉ាប់រង	1	2	3	4	5	6	7	8	9	10	.....	35	អត្ថប្រយោជន៍ពេលដល់កាលកំណត់
បុព្វលាភធានារ៉ាប់រង	7,500	7,500	7,500	7,500	7,500	7,500	7,500						
មរណភាព/ពិការភាពមិនដោយសារគ្រោះថ្នាក់ចៃដន្យ	10,000	20,000	30,000	40,000	50,000	60,000	70,000						
មរណភាព / ពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ	30,000	60,000	90,000	120,000	150,000	180,000	210,000						
ចំណូលប្រចាំឆ្នាំ		500	500	500	500	500	500						



ចំណូលប្រចាំឆ្នាំសរុប **$3,000** + មរណភាព/ពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ **$210,000** = អត្ថប្រយោជន៍សរុប **$213,000** | បុព្វលាភធានារ៉ាប់រងសរុប **$52,500**

ចំណុចគួរយល់ដឹងមុននឹងទិញផលិតផលនេះ៖

ពិការភាពទាំងស្រុង និង ជាអចិន្ត្រៃយ៍៖	**ជាការបាត់បង់ទាំងស្រុង និងជាអចិន្ត្រៃយ៍ ដូចខាងក្រោម៖** ក. ការបាត់បង់ទាំងស្រុងដែលមិនអាចព្យាបាលបានជារៀងរហូតនៃភ្នែកទាំងពីរ ឬ ខ. ការបាត់បង់ទាំងស្រុងដែលមិនអាចព្យាបាលបានជារៀងរហូតនៃអវយវៈទាំងពីរនៅត្រង់កដៃ/កជើង ឬនៅផ្នែកខាងលើនៃកដៃ/កជើង ឬ គ. ការបាត់បង់ទាំងស្រុងដែលមិនអាចព្យាបាលបានជារៀងរហូតនៃភ្នែកម្ខាង ឬការបាត់បង់ទាំងស្រុងដែលមិនអាចព្យាបាលបានជារៀងរហូតនៃអវយវៈមួយនៅត្រង់កដៃ/កជើង ឬនៅផ្នែកខាងលើនៃកដៃ/កជើង
រយៈពេលសាកល្បង/ រយៈពេលពិចារណា 21ថ្ងៃ៖	លោកអ្នកមានរយៈពេល (21)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ដើម្បីពិនិត្យពីលក្ខណៈសម្បត្តិ និងអត្ថប្រយោជន៍នៃគម្រោងនេះ និងលក្ខខណ្ឌសំខាន់ៗ។ ប្រសិនជា ក្នុងរយៈពេលនេះលោកអ្នកមានអារម្មណ៍ថាមិនពេញចិត្តនឹងគម្រោងនេះ លោកអ្នកអាចលុបចោលបណ្ណសន្យារ៉ាប់រងបាន ហើយក្រុមហ៊ុននឹងបង្វិលបុព្វលាភធានារ៉ាប់រងដែលលោកអ្នកបានបង់ជូនវិញ ដោយដកចំនួនប្រាក់ណាមួយដែលនៅជំពាក់ក្រុមហ៊ុន (ប្រសិនបើមាន)។
លក្ខខណ្ឌ	ដែលបានបញ្ជាក់ក្នុងខិត្តប័ណ្ណនេះ មិនមែនជាលក្ខខណ្ឌទាំងអស់ឡើយ។ សម្រាប់ព័ត៌មានបន្ថែម សូមពិគ្រោះជាមួយភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល ឬបុគ្គលិកលក់របស់យើងខ្ញុំ និងសូមយោងទៅតាម ខ និងលក្ខខណ្ឌ លម្អិតនៃផលិតផល។

ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ការអស់សុពលភាពជាបណ្តោះអាសន្ន ការផ្អាកកិច្ចសន្យាធានារ៉ាប់រង និងការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ

វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងការបន្តបង់បុព្វលាភធានារ៉ាប់រងឱ្យបានទៀងទាត់ និងទាន់ពេលវេលា ដើម្បីបន្តអត្ថប្រយោជន៍ធានារ៉ាប់រងដែលនឹងត្រូវទទួលបាន ក្រោមបណ្ណសន្យារ៉ាប់រង។ បណ្ណសន្យារ៉ាប់រង នឹងក្លាយជាបណ្ណសន្យារ៉ាប់រងដែលអស់សុពលភាពជាបណ្តោះអាសន្ន ប្រសិនបើលោកអ្នកខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រងសរុប រហូតដល់ថ្ងៃផុតកំណត់នៃរយៈពេលអនុគ្រោះដែលមានរយៈពេលហុកសិប (60) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រង។

លោកអ្នកមានរយៈពេល 24ខែ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងអស់សុពលភាពជាបណ្តោះអាសន្នដើម្បីធ្វើការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ។ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រង មិនបានស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រង ក្នុងរយៈពេល ម្ភៃបួន (24) ខែ ដោយគិតចាប់ថ្ងៃដែលបណ្ណសន្យារ៉ាប់រងនោះអស់សុពលភាពជាបណ្តោះអាសន្នទេនោះ ក្រុមហ៊ុននឹងបញ្ចប់បណ្ណសន្យារ៉ាប់រង និងទូទាត់តម្លៃនៃការបោះបង់កិច្ចសន្យារ៉ាប់រងដែលអាចទទួលបាន គិតត្រឹមកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងអស់សុពលភាពជាបណ្តោះអាសន្ន។

លោកអ្នកមានសិទ្ធិបោះបង់បណ្ណសន្យារ៉ាប់រងរបស់លោកអ្នកនៅពេលណាក៏បាន ក្នុងរយៈពេលនៃបណ្ណសន្យារ៉ាប់រងរបស់លោកអ្នក។ ក្រុមហ៊ុនត្រូវទូទាត់តម្លៃនៃការបោះបង់កិច្ចសន្យាធានារ៉ាប់រង ជូនម្ចាស់បណ្ណសន្យារ៉ាប់រង។ បន្ទាប់ពីក្រុមហ៊ុនទូទាត់តម្លៃនៃការបោះបង់កិច្ចសន្យារ៉ាប់រងនេះរួច បណ្ណសន្យារ៉ាប់រងនេះនឹងអស់សុពលភាព ហើយអត្ថប្រយោជន៍ពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះទាំងអស់នឹងត្រូវបញ្ចប់ផងដែរ។

ករណីមិនធានារបស់ផលិតផល៖

សេចក្តីសង្ខេបករណីមិនធានាសម្រាប់ផលិតផល PRUទ្រព្យ អេលីត រួមមាន៖

ក) ករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារករណីគ្រោះថ្នាក់ចៃដន្យ ឬមិនមែនគ្រោះថ្នាក់ចៃដន្យ៖	• ការធ្វើអត្តឃាត ឬធ្វើឱ្យរបួសខ្លួនឯង ក្នុងរយៈពេល 2ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង • មេរោគអេដស៍ និង/ឬជម្ងឺណាមួយដែលជាប់ទាក់ទងនឹងមេរោគអេដស៍ • ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានា ឬអ្នកទទួលផល • ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ
ខ) ករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារគ្រោះថ្នាក់ចៃដន្យ៖	• ករណីមិនធានាដែលមាននៅក្នុងចំណុច ក • ការចូលរួមនៅក្នុងសកម្មភាពកីឡាដែលងាយមានគ្រោះថ្នាក់ • ការចូលរួមក្នុងសកម្មភាពអាកាសចរណ៍នានា លើកលែងតែជាអ្នកដំណើរដែលត្រូវបង់ប្រាក់ថ្លៃធ្វើដំណើរ តាមយន្តហោះពហុម៉ាស៊ីនយន្តហោះមានកាលវិភាគធ្វើដំណើរត្រឹមត្រូវ និងយន្តហោះមានអាជ្ញាបណ្ណធ្វើពាណិជ្ជកម្មត្រឹមត្រូវ • សកម្មភាពសង្គ្រាម ឬអំពើហិង្សា • រាល់ជម្ងឺដែលបណ្តាលមកពីការខាំ ឬចិច ដោយសត្វល្អិត រួមទាំងមូសខាំ និងដង្កូវ ឬសត្វល្អិតរាតត្បាតក្នុងរាងកាយ។

សូមទៅកាន់ឯកសារនៃបណ្ណសន្យារ៉ាប់រងសម្រាប់ព័ត៌មានបន្ថែមលើករណីមិនធានា។

PRUទ្រព្យ អេលីត


បង្កើនទ្រព្យសម្បត្តិ *ការពារមរតកគ្រួសារ*



ទំនាក់ទំនងមកយើងខ្ញុំ

023 964 222

1800-21 22 23



Prudential Cambodia

Prudential Cambodia

info@prudential.com.kh

www.prudential.com.kh

Prudential (Cambodia) Life Assurance

អាគារជីបម៉ុង ថៅរើ ជាន់ទី២០ ស្ថិតនៅមហាវិថីសហព័ន្ធរុស្សី (១១០) ភូមិ១០ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា